# អង្គការមិត្តសំឡាញ់
# អបអរសាទរខួបទី៦៦ ទិវាកុមារអន្តរជាតិ១មិថុនា
# និងខួបទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា
# នឹងប្រព្រឹត្តទៅនាថ្ងៃសុក្រ ទី២៩ ខែ ឧសភា ឆ្នាំ ២០១៥

ឆ្នាំនេះអង្គការមិត្តសំឡាញ់បានរៀបចំអបអរសាទរទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី៦៦ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ខួបលើកទី១៤នៅថ្ងៃសុក្រ ទី២៩ ខែ ឧសភា ឆ្នាំ ២០១៥ ចាប់ពីព្រឹកម៉ោង៩: 00រហូតដល់រសៀលម៉ោង៤:00ក្រោមប្រធានបទ

« លើកកម្ពស់អាហារូបត្ថម្ភប្រកបដោយគុណភាព ដើម្បីអភិវឌ្ឍកុមារ » និង

« បញ្ឈប់ពលកម្មកុមារ ផ្តល់ការអប់រំដែលមានគុណភាព »

**ក្នុងគោលបំណង**

- ដើម្បីរំលឹកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់ យើងទាំងអស់គ្នាចំពោះបញ្ហាកុមារ ស្របតាមរដ្ឋធម្មនុញ្ញ អនុសញ្ញាស្តីពី សិទ្ធកុមាររបស់អង្គការសហប្រជាជាតិ ។
- លើកកម្ពស់អាហារូបត្ថម្ភប្រកបដោយគុណភាព ដើម្បីអភិវឌ្ឍកុមារនិងសំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដូចជាទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពងាយរងគ្រោះ។

កម្មវិធីនេះរៀបចំដោយកុមារយុវវ័យ និងមិត្តអប់រំមិត្ត របស់អង្គការមិត្តសំឡាញ់ ដោយមានការគាំទ្រពីបុគ្គលិក ហើយមានការចូលរួមពីកុមារ/យុវវ័យ មកពីតាមថ្នល់ សហគមន៍ កុមារ/យុវវ័យ មកពី អង្គការ ដៃគូរ នានា ម្ចាស់ជំនួយ និងអាជ្ញាធរដែនដី ដែលមានចំនួនសរុប ប្រមាណ៦០០នាក់។

**ដំណើរការកម្មវិធី**

- ព្រឹកចាប់ពីម៉ោង៩:00រហូតដល់ម៉ោង១១:00 កុមារ/យុវវ័យអាចចូលរួមគូររូបភាពដែលទាក់ទងប្រធានបទ។
- ពីម៉ោង២:០០ដល់ម៉ោង៤:០០រសៀល កម្មវិធីសិល្បៈ ការបង្ហាញពីអត្ថន័យនៃផ្ទាំងគំនូររបស់អ្នកចូលរួមគូរនៅលើផ្ទាំងក្រណាត់ សំនួរចម្លើយ និង ល្បែងកំសាន្តនៅ អង្គការមិត្តសំឡាញ់ ផ្ទះលេខ ២១៥ ផ្លូវ១៣ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ ។

កម្មវិធីនេះអាចដំណើការទៅបានដោយមានការឧបត្ថមថវិកាអង្គការសំឡាញ់និងពីម្ចាស់ជំនួយ /PLW/SCA/EU និង ក្រោមការឧបត្ថមបច្ចេកទេសពីអង្គការ Friends International។

យើងខ្ញុំសង្ឃឹមថាបុគ្គលិកមិត្តសំឡាញ់ និងFriends Internationalនឹងសហការគ្នាល្អក្នុងការ រៀបចំកម្មវិធីនេះឲ្យទទួលបានជោគជ័យ ជាពិសេសអាជ្ញាធរដែនដីអង្គការដៃគូរដែល នឹងបានចូលរួមគ្រប់ៗគ្នាពិសេសប្រព័ន្ធផ្សព្វផ្សាយនានា នឹងមកយកពត៌មានចាក់ផ្សាយ កម្មវិធីយើងខ្ញុំសំរាប់សាធារណៈជន ។

សូមអរគុណ!